ព្រះរាជក្រឹត្យ

នស/រកត/០៤១៦/៤១៦

ស្តីពី

ការប្រគល់រមណីយដ្ឋានប្រាសាទកោះកែរ ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់
អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្រ្ទាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៤/០៧០ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៤ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទកោះកែរ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៤៨ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដើម្បីការពារនិងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១១/៧៥២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១១ ស្តីពីការកំណត់តំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ ..**

ប្រគល់រមណីយដ្ឋានប្រាសាទកោះកេរ ដែលស្ថិតនៅក្នុងភូមិស្រយង់ ឃុំស្រយង់ ស្រុកគូលែន ខេត្តព្រះវិហារ ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ។

**មាត្រា២ ..**

អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ មានសិទ្ធិធ្វើការកំណត់ ការចាត់ចែង ការការពារ ការត្រួតពិនិត្យ ការអភិរក្ស ការអភិវឌ្ឍន៍ និងការលើកតម្លៃបេតិកភណ្ឌវប្បធម៌ធម្មជាតិ ស្របតាមប្លង់កំណត់មួយដែលមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៥០៤/០៧០ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៤ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទកោះកេរ។

**មាត្រា៣ ..**

ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៥/៣២៣ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៥ ស្តីពីការប្រគល់រមណីយដ្ឋានប្រាសាទកោះកេរ ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរ "អប្សរា" និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ ..**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី២៦ ខែ មេសា ឆ្នាំ២០១៦

នរស.១៦០៤.៤២២

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ហត្ថលេខា**
**សុខ អាន**

លេខ: ៤២៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ មេសា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខ:**